# ការប្រកាសប្រាប់
# ដើម្បីយកឈ្នះ
# វិញ្ញាណអាក្រក់

សូមថ្លែងទីបន្ទាល់ទៅកាន់សាតាំងដោយផ្ទាល់តាមរយៈព្រះបន្ទូលរបស់ទ្រង់ថា **ព្រះលោហិត** របស់ទ្រង់គឺសំរាប់ខ្ញុំ (១)

ដោយសារព្រះលោហិតរបស់ព្រះយេស៊ូវ ខ្ញុំបានរំដោះពីកណ្តាប់ដៃរបស់មារសាតាំង (២)

ដោយសារព្រះលោហិតរបស់ព្រះយេស៊ូវ អំពើបាបរបស់ខ្ញុំត្រូវបានអត់ទោស (២ក)

ដោយសារព្រះលោហិតរបស់ព្រះយេស៊ូវ ដែលជាបុត្រារបស់ព្រះជាម្ចាស់ បានសំអាតទូលបង្គំអោយរួចផុតពីអំពើបាបទាំងអស់ (៣)

ដោយសារព្រះលោហិតរបស់ព្រះយេស៊ូវ ខ្ញុំបានក្លាយទៅជាមនុស្សសុចរិត បើទោះជាខ្ញុំប្រព្រឹត្តអំពើបាប ឬមិនដែលប្រព្រឹត្តអំពើបាបក៏ដោយ(៤)

ដោយសារព្រះលោហិតរបស់ព្រះយេស៊ូវ ខ្ញុំបានញែកចេញជាបរិសុទ្ធ គឺបានញែកចេញជាបរិសុទ្ធនៅចំពោះព្រះជាម្ចាស់ (៥)

រូបកាយរបស់ខ្ញុំគឺជាព្រះវិហារ នៃព្រះវិញ្ញាណបរិសុទ្ធ ទ្រង់បានប្រោសលោះនិងលាងសំអាតដោយព្រះលោហិតរបស់ព្រះយេស៊ូវគ្រីស្ទ(៦)

**អារក្សសាតាំងគ្មានអំណាច និងមិនអាចមកគ្រប់គ្រង់ជីវិតរបស់ខ្ញុំទេ គឺដោយសារតែ ព្រះលោហិតរបស់ព្រះយេស៊ូវគ្រីស្ទ !**

| | | | |
|---|---|---|---|
| (១) | វិវរណៈ ១២ : ១១ | (៤) | រ៉ូម ៥ : ៩ |
| (២) | អេភេសូរ ១ : ៧ | (៥) | ហេព្រើរ ១៣ : ១២ |
| (២ក) | ទំនុកតម្កើង ១០៧: ២ | (៦) | ១កូរិនថូស ៦ : ១៩-២០ |
| (៣) | ១យ៉ូហាន ១ : ៧ | | |

**វិវរណៈ ១២: ១១** គេបានឈ្នះវា ដោយសារឈាមនៃកូនចៀម ហើយដោយសារសេចក្តីបន្ទាល់របស់គេ ក៏មិនបានស្តាយជីវិតខ្លួនដរាបដល់ស្លាប់។

**អេភេសូរ ១: ៧** ហើយយើងបានសេចក្តីប្រោសលោះនៅក្នុងព្រះរាជបុត្រានោះ ដោយសារព្រះលោហិតទ្រង់ គឺជាសេចក្តីប្រោសឲ្យរួច ពីទោស តាមព្រះគុណដ៏ធ្ងន់ក្រៃលែងនៃទ្រង់ ។

**ទំនុកតម្កើង១០៧: ២** គួរឲ្យពួកអ្នកដែលព្រះយេហូវ៉ាបានប្រោសលោះ បានថាដូច្នេះដែរ គឺអស់អ្នកដែលទ្រង់បានលោះឲ្យរួចពីកណ្តាប់ដៃនៃពួកខ្មាំងសត្រូវនោះ។

**១យ៉ូហាន ១: ៧** តែបើយើងរាល់គ្នាដើរក្នុងពន្លឺវិញ ដូចជាទ្រង់ក៏គង់ក្នុងពន្លឺដែរ នោះយើងមានសេចក្តីប្រកបនឹងគ្នាទៅវិញទៅមក ហើយព្រះលោហិតនៃព្រះយេស៊ូវគ្រីស្ទ ជាព្រះរាជបុត្រានៃទ្រង់ ក៏សំអាតយើងរាល់គ្នា ពីគ្រប់អំពើបាបទាំងអស់។

**រ៉ូម ៥: ៩** ដូច្នេះ ដែលបានរាប់ជាសុចរិត ដោយសារព្រះលោហិតទ្រង់នោះប្រាកដជាយើងនឹងបានរួចចេញពីសេចក្តីក្រោធ ដោយសារទ្រង់ជាមិនខានលើសទៅទៀត ។

**ហេព្រើរ ១៣: ១២** ដូច្នេះ ព្រះយេស៊ូវទ្រង់ក៏បានរងទុក្ខ នៅខាងក្រៅទ្វារក្រុងដែរ ដើម្បីនឹងញែកប្រជាជនឲ្យបរិសុទ្ធ ដោយសារព្រះលោហិតនៃអង្គទ្រង់ ។

**១កូរិនថូស ៦: ១៩-** តើមិនដឹងទេឬអីថា រូបកាយអ្នករាល់គ្នាជាវិហារនៃព្រះវិញ្ញាណបរិសុទ្ធ ដែលអ្នករាល់គ្នាបានទទួលមកពីព្រះ ហើយអ្នករាល់គ្នាមិនមែនជារបស់ផងខ្លួនទេ ២០ ដ្បិតព្រះទ្រង់បានចេញថ្លៃលោះអ្នករាល់គ្នាហើយ ដូច្នេះ ចូរដំកើងព្រះនៅក្នុងរូបកាយ ហើយក្នុងវិញ្ញាណនៃអ្នករាល់គ្នា ដែលជារបស់ផងទ្រង់ចុះ។

**បកប្រែដោយ: ONE -2 -ONE CAMBODIA**
**អាស័យដ្ឋានៈ # ៣៨ - ៣៨A ផ្លូវលេខ ៣៣៦**
**សង្កាត់ទឹកល្អក់៣ ខ័ណ្ឌទួលគោក**
**រាជធានីភ្នំពេញ ប្រទេសកម្ពុជា**
www.One-2-One world.org
www.derekprince.co.nz PC03